**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំ
ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# ដំណឹងជ្រើសរើស
# មន្ត្រីបច្ចេកទេសរៀបចំស្តង់ដាថ្លៃដើម

( Cost Standard )

ចាប់តាំងពីចុងឆ្នាំ២០០៤មក រាជរដ្ឋាភិបាលកម្ពុជាដោយមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានចាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាជំហានៗ ដែលមានគោលបំណងកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាឆ្ពោះទៅរកស្តង់ដាអន្តរជាតិ។ ការអនុវត្តកម្មវិធីនេះបានទទួលជោគជ័យជាបន្តបន្ទាប់ ហើយកំពុងបន្តអនុវត្តជំហានបន្ទាប់ទៀត។ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) ជាសេនាធិការរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានមុខងារ និង ភារកិច្ចសម្របសម្រួលការរៀបចំ និងការអនុវត្តការងារគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ព្រមទាំងសម្របសម្រួលការរៀបចំ និងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ដោយមានចក្ខុវិស័យច្បាស់លាស់ និងក្នុងនាមជាសេនាធិការប្រកបដោយគុណភាព សក្តិសិទ្ធភាព និងប្រសិទ្ធភាព អ.គ.ហ មានតម្រូវការជ្រើសរើស **មន្ត្រីបច្ចេកទេសរៀបចំស្តង់ដាថ្លៃដើម** (Cost Standard) (**មន្ត្រីជាប់កិច្ចសន្យា**) បម្រើការងារជូននាយកដ្ឋានប្រសិទ្ធភាពចំណាយ នៃអគ្គនាយកដ្ឋានគោលនយោបាយ ដែលមានគុណវុឌ្ឍិការងារដូចខាងក្រោម៖

❖ **គុណវុឌ្ឍិទូទៅ**

- មានសញ្ញាបត្រកម្រិតបរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់ទាក់ទងនឹងជំនាញសេដ្ឋកិច្ច, ហិរញ្ញវត្ថុ, គ្រប់គ្រង, ស្ថិតិ ឬជំនាញពាក់ព័ន្ធផ្សេងៗ,
- មានបទពិសោធពាក់ព័ន្ធនឹងជំនាញបានរៀបរាប់ខាងលើ ជាពិសេស បទពិសោធពាក់ព័ន្ធក្នុងវិស័យសាធារណៈ យ៉ាងតិច ០៣ ឆ្នាំ,
- មានការយល់ដឹងអំពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, កិច្ចដំណើរគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ហិរញ្ញវត្ថុសាធារណៈ,
- មានការយល់ដឹងអំពីស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា,
- មានសមត្ថភាពប្រើប្រាស់កម្មវិធី Microsoft Word, Excel និង Power Point បានល្អ,
- មានសមត្ថភាពក្នុងការអាន ស្តាប់ សរសេរ និងនិយាយ ភាសាខ្មែរ និងភាសាអង់គ្លេស,
- មានការអត់ធ្មត់ខ្ពស់ ធន់នឹងសម្ពាធការងារ មានទំនាក់ទំនងល្អជាមួយក្រុមការងារ និងចេះធ្វើការងារជាក្រុម។

❖ **ឯកសាភ្ជាប់**

- បេក្ខជន ឬបេក្ខនារីដែលមានចំណាប់អារម្មណ៍ សូមមកដាក់ពាក្យសុំចូលបម្រើការងារដោយភ្ជាប់មកជាមួយនូវ៖
- ប្រវត្តិរូបសង្ខេប (CV) និង Cover Letter (ជាភាសាអង់គ្លេស)

- សញ្ញាបត្របញ្ជាក់ការសិក្សាថតចម្លង លិខិតបញ្ជាក់បទពិសោធន៍ការងារ និងឯកសារពាក់ព័ន្ធនានា
- ភ្ជាប់មកជាមួយឈ្មោះអ្នកសំអាង (referees)ចំនួនពីររូប

❖ **ការជ្រើសរើស**

ការជ្រើសរើសត្រូវធ្វើឡើងតាមរយៈការធ្វើតេស្តសមត្ថភាពលើវិញ្ញាសាសរសេរ និងការសម្ភាសន៍ផ្ទាល់មាត់ពីគណៈកម្មាធិការជ្រើសរើស។ ការជ្រើសរើសនេះត្រូវបានបើកចំហដល់បេក្ខជន ឬបេក្ខនារីទាំងអស់មកពីគ្រប់ក្រសួងស្ថាប័ន និងសាធារណៈជន។

❖ **ការដាក់ពាក្យស្នើសុំជ្រើសរើស**

បេក្ខជន/បេក្ខនារីដែលមានចំណាប់អារម្មណ៍សូមផ្ញើបច្ចុប្បន្នភាពប្រវត្តិរូបសង្ខេប ដោយបញ្ជាក់ពីជំនាញ បច្ចេកទេស និងបទពិសោធន៍ដូចដែលមានចែងខាងលើ ព្រមទាំងឯកសារពាក់ព័ន្ធតាមរយៈសារអេឡិចត្រូនិច Email: hr@pfm.gov.kh យ៉ាងយូរបំផុតត្រឹម***ថ្ងៃអង្គារ ៨កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩ ត្រូវនឹងថ្ងៃទី២៤ ខែកុម្ភៈ គ.ស. ២០២៦ វេលាម៉ោង ៥ និង ៣០នាទីល្ងាច***។ អ.គ.ហ. ទទួលពាក្យស្នើសុំចុះឈ្មោះចូលបម្រើការងារតាមរយៈប្រព័ន្ធអនឡាញ (Online) តែប៉ុណ្ណោះ។

*ចំណាំ៖ មានតែបេក្ខជន/បេក្ខនារីដែលបានជាប់ជម្រុះបឋម (Shortlisted) តែប៉ុណ្ណោះ ដែលនឹងត្រូវអញ្ជើញមកសម្ភាសន៍ផ្ទាល់មាត់។*

❖ **ព័ត៌មានបន្ថែម**

សូមទាញយកលក្ខខណ្ឌយោងតាមគេហទំព័រ http://www.pfm.gov.kh/index.php/km/job-vacancy-kh។

ព័ត៌មានបន្ថែម សូមទាក់ទងមកលេខទូរស័ព្ទ ឬតាមអាសយដ្ឋានដូចខាងក្រោម៖

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
បន្ទប់អគ្គលេខាធិការដ្ឋានកំណែទម្រង់ អគារ "ក" ជាន់ទី៣
ទូរស័ព្ទទាក់ទង : ០៨៥ ៧៧៧ ៩២០ /អ៊ីមែល/Email: hr@pfm.gov.kh